# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីលទ្ធផលសន្និសីទថ្នាក់រដ្ឋមន្ត្រីមហាអនុតំបន់ទន្លេមេគង្គ (GMS)
# លើកទី១៦ នៅទីក្រុងហាណូយប្រទេសវៀតណាម

ដោយទទួលការអនុញ្ញាតិពីរាជរដ្ឋាភិបាលកម្ពុជា ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជារដ្ឋមន្ត្រីទទួលបន្ទុកកម្មវិធីមហាអនុតំបន់មេគង្គសម្រាប់កម្ពុជា បានដឹកនាំគណៈប្រតិភូអន្តរក្រសួង អមដំណើរដោយឯកឧត្តម **សុខ ចិន្តា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងជាអ្នកសម្របសម្រួលជាតិកម្មវិធីមហាអនុតំបន់មេគង្គ តំណាងមកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្រសួងពាណិជ្ជកម្ម ក្រសួងសាធារណការ និងដឹកជញ្ជូន អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងលេខាធិការដ្ឋានជាតិមហាអនុតំបន់ទន្លេមេគង្គ ដើម្បីអញ្ជើញទៅចូលរួមក្នុងសន្និសីទ ថ្នាក់រដ្ឋមន្ត្រីមហាអនុតំបន់ទន្លេមេគង្គលើកទី១៦ កោមប្រធានបទ"**មហាអនុតំបន់ទន្លេមេគង្គ ក្នុងទស្សវត្សថ្មី :ដែនថ្មី នៃកិច្ចសហប្រតិបត្តិការ**" ដែលបានប្រារព្ធធ្វើនៅទីក្រុងហាណូយ ប្រទេសវៀតណាម ពីថ្ងៃទី១៩-២០ ខែ សីហា ឆ្នាំ២០១០ ដើម្បីបង្ហាញពីគោលជំហរ និងការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងការអនុវត្តកម្មវិធីមហាអនុតំបន់ទន្លេមេគង្គ ។






នៅក្នុងកិច្ចប្រជុំនោះ ឯកឧត្តម **Vo Hong Phuc** រដ្ឋមន្ត្រីក្រសួងផែនការ និងវិនិយោគ និងជារដ្ឋមន្ត្រីមហាអនុតំបន់មេគង្គសម្រាប់វៀតណាម បានធ្វើជាសហប្រធាននៃសន្និសីទថ្នាក់រដ្ឋមន្ត្រីមហាអនុតំបន់ទន្លេមេគង្គលើកទី១៦ ជាមួយ ឯកឧត្តម **C. Lawrence Greenwood,** អនុប្រធានធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលជាស្ថាប័នគាំទ្រដ៏សំខាន់ ក្នុងកម្មវិធីសហប្រតិបត្តិការសេដ្ឋកិច្ចក្នុងមហាអនុតំបន់មេគង្គ ។

ក្នុងអង្គពិធី សន្និសីទបានធ្វើការពិនិត្យឡើងវិញនូវវឌ្ឍនភាពសំខាន់ៗ នៃផែនការសកម្មភាពទីក្រុងវៀងច័ន្ទ ពីឆ្នាំ ២០០៨ ដល់ឆ្នាំ២០១២ ដែលក្នុងនោះ រួមមានៈ សកម្មភាពក្នុងវិស័យដឹកជញ្ជូន ទូរគមនាគមន៍ ទេសចរណ៍ បរិស្ថាន កសិកម្ម ពាណិជ្ជកម្ម ថាមពលនិងអភិវឌ្ឍន៍ធនធានមនុស្ស ។

ឆ្លងកាត់កិច្ចប្រជុំពិភាក្សារួចមក អង្គសន្និសីទ បានផ្តល់ការឯកភាពដូចខាងក្រោមៈ

-កម្មវិធីសកម្មភាពសម្រាប់កិច្ចសម្រួលពាណិជ្ជកម្ម និងការដឹកជញ្ជូន ដែលធ្វើឱ្យកាន់តែប្រសើរឡើងនូវភាពប្រកួតប្រជែង និងប្រែក្លាយរបៀងដឹកជាញ្ជូន ទៅជារបៀងសេដ្ឋកិច្ច ។ នៅក្នុងកិច្ចប្រជុំនោះ រដ្ឋមន្ត្រី GMS និងដៃគូអភិវឌ្ឍន៍ បានយល់ស្របគ្នា លើសារៈសំខាន់ លើការអភិវឌ្ឍន៍ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធផ្នែកទន់ ជាពិសេសកិច្ចសម្រួលពាណិជ្ជកម្ម និងការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ដែលនឹងបង្កើនអត្ថប្រយោជន៍ទទួលបានពីហេដ្ឋារចនាសម្ព័ន្ធផ្នែករឹង ។ ដូច្នេះ កម្មវិធីសកម្មភាពនេះ នឹងបំរើជាត្រីវិស័យសម្រាប់ជំរុញការងារក្នុងវិស័យសំខាន់ៗ ដូចជាៈ ការដាក់ឱ្យអនុវត្តប្រព័ន្ធឆ្លងកាត់គយ អនាម័យ និងភូត្តគាមអនាម័យ ក៏ដូចជាមូលដ្ឋានដើម្បីគៀងគរជំនួយពីដៃគូរអភិវឌ្ឍន៍ ។

-ក្របខ័ណ្ឌជាយុទ្ធសាស្ត្រ សម្រាប់តភ្ជាប់ផ្លូវដែក ដែលជាជំហ៊ានដំបូងដ៏សំខាន់មួយ ឆ្ពោះទៅរកការតភ្ជាប់ប្រព័ន្ធផ្លូវដែក ក្នុង GMS ។

-ទិសដៅជាយុទ្ធសាស្ត្រ និងផែនការសម្រាប់កិច្ចអភិវឌ្ឍន៍ជំហ៊ានទី២ នៃកម្មវិធីបរិស្ថានស្នូលរបស់ GMSនិងគំនិតផ្តួចផ្តើមរបៀបអភិរក្សជីវចម្រុះ រួមមានៈ **១**-ការអភិរក្សជីវចម្រុះ និងកាត់បន្ថយភាពក្រីក្រ **២**-ការប្រែប្រួលអាកាសធាតុ **៣**-ការគ្រប់គ្រងបរិស្ថានជនបទ **៤**-ការកសាងសមត្ថភាព ។

-ជំនួយបច្ចេកទេស សម្រាប់ថាមពលកកើតឡើងវិញ ឥទ្ធនៈមិនប៉ះពាល់បរិស្ថាន និងការប្រើប្រាស់ថាមពលឱ្យមានប្រសិទ្ធិភាព ។

-កម្មវិធីគាំទ្រកសិកម្មគន្លឹះជំហ៊ានទី២ (២០១១-២០១៥) ដែលនឹងធ្វើឱ្យមានភាពកាត់តែប្រកួតប្រជែង ក្នុងការផលិត និងធានាសន្តិសុខស្បៀង ។

- យុទ្ធសាស្ត្រ និងផែការសកម្មភាព សម្រាប់របៀងសេដ្ឋកិច្ចភាគខាងត្បូង ដែលជាក្របខ័ណ្ឌសំរាប់លើកកំពស់ការសម្របសម្រួល និងការអនុវត្តន៍គំនិតផ្តួចផ្តើម និងការគាងគរធនធាន ដើម្បីអភិវឌ្ឍន៍របៀងសេដ្ឋកិច្ចភាគខាងត្បូង ។ បន្ថែមលើនេះ រដ្ឋមន្ត្រី បានពិភាក្សា និងផ្តល់ធាតុចូល សម្រាប់កសាងក្របខ័ណ្ឌយុទ្ធសាស្ត្រ(២០១២-២០២២) សម្រាប់អភិវឌ្ឍន៍ GMS ។ ធាតុចូលសំខាន់ៗ ដែលបានឯកភាពគ្នា រួមមានៈ

-ការបញ្ចៀស និងការសម្រប និងការបម្រែបម្រួលអាកាសធាតុ

-ការគ្រប់គ្រងនិងការប្រើប្រាស់ធនធានទឹកទន្លេមេគង្គឱ្យមានប្រសិទ្ធភាព និងតុល្យភាព សម្រាប់ផលិតថាមពលអគ្គិសនី និងគាំទ្រវិស័យកសិកម្ម និងផលិតកម្មស្រូវ ។

-បង្កើតកម្មវិធីកសាងផ្លូវលំជនបទ និងទីក្រុង ដោយគោរពគោលការណ៍បរិស្ថាន (ECO-Friendly Town )

-ផ្តោតការយកចិត្តទុកដាក់ លើការកសាង ហេដ្ឋារចនាសម្ព័ន្ធ ផ្នែកទន់ និងការអភិវឌ្ឍន៍ធនធានមនុស្ស ។

ដោយឡែក ជាជំហរ ដៃគូអភិវឌ្ឍន៍ បានសំដែងនូវការគាំទ្រចំពោះកម្មវិធី GMS តាមរយៈការផ្តល់ហិរញ្ញប្បទានធាតុចូលផ្នែកគោលនយោបាយ/ស្ថាប័ន ការកសាងសមត្ថភាព ជនួយបច្ចេកទេស មូលដ្ឋានចំណេះដឹង និងចែករំលែកបទពិសោធន៍ ។ ដៃគូអភិវឌ្ឍន៍ ក៏នឹងបន្តជួយដល់កម្មវិធីកិច្ចសម្រួលពាណិជ្ជកម្ម និងករដឹកជញ្ជូន ការបញ្ចៀស និងការសម្របទៅនិងបម្រែបម្រួលអាកាសធាតុ ការអភិវឌ្ឍន៍ធនធានទឹកចម្រុះក្នុងអាងទន្លេមេគង្គ ការធ្វើកសិកម្មសម្រាប់ពាណិជ្ជកម្មនិងសន្តិសុខស្បៀង ថាមពលកកើតឡើងវិញនៅជនបទ ការអភិវឌ្ឍន៍ធនធានមនុស្ស ការគាំទ្រស្ថាប័នអនុតំបន់ និងលើកកំពស់ភាពជាដៃគូ រវាងផ្នែកឯកជននិងសាធារណៈ ។

គួរបញ្ជាក់ថាៈ ចាប់តាំងពីឆ្នាំ១៩៩២ ប្រទេសកម្ពុជា-ចិន-ឡាវ-ភូមា-ថៃ-វៀតណាម ដែលជាប្រទេសស្ថិតក្នុងមហាអនុតំបន់ទន្លេមេគង្គ ហើយទទួលបាននូវគំរោងគាំទ្រពីដៃគូរអភិវឌ្ឍន៍ និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានចូលរួមក្នុងកម្មវិធីទូលំទូលាយនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច គ្របដណ្តប់ទៅលើ-ផ្នែកដឹកជញ្ជូន-ថាមពល-ទូរគមនាគមន៍-ការអភិវឌ្ឍន៍ធនធានមនុស្ស-បរិស្ថាននិងការគ្រប់គ្រងប្រភពធនធាន-កិច្ចសម្រួលពាណិជ្ជកម្ម-ការវិនិយោគឯកជន-ទេសចរណ៍ និងកសិកម្ម ។ ចាប់តាំងពីគម្រោងកម្មវិធីបានចាប់ផ្តើម គិតមកដល់ចុងឆ្នាំ២០០៩ ដៃគូអភិវឌ្ឍន៍ បានផ្តល់គំរោងគាំទ្រផ្នែកហិរញ្ញវត្ថុ ជាមួយប្រភពជំនួយផ្លូវការ ប្រមាណជិត ៣ពាន់ ៥០០លានដុល្លាសហរដ្ឋអាមេរិក($3.5 Billion) ។